# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌលេខ ៤២ "ជ១" ក្រ១១
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៦០
ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣
-សំណុំរឿងស៊ើបសួរលេខ ១៦១៥
ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤
-សំណុំរឿងជំនុំជម្រះលេខ ៥៨០៦
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ : ០០ នាទី នៅសាលសវនាការទី២ ជាន់ទី១ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣១៦០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ឡាង** ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសន្តិសុខក្រុមហ៊ុនពន្លឺអង្គរ អាសយដ្ឋានបច្ចុប្បន្ននៅក្រុមហ៊ុន ភូមិល្វប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ (គេចខ្លួន)

<u>ជាប់ចោទពីបទ៖</u> **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចប្រៃស្វាត់ក្បែរសន្តិសុខក្រុមហ៊ុនពន្លឺអង្គរ ភូមិល្វប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] សាវឿន អាយុ៤១ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី និងឈ្មោះ [redacted] បូណា ភេទស្រី អាយុ១៤ឆ្នាំ ជាជនរងគ្រោះ មានទីលំនៅបច្ចុប្បន្ននៅភូមិកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៩ និង៣០នាទី មានករណីរំលោភសេពសន្ថវៈមួយបានកើតឡើង ដែលបង្ករដោយជនសង្ស័យឈ្មោះ [redacted] ឡាង បានធ្វើសកម្មភាពចាប់រំលោភជនរងគ្រោះ ឈ្មោះ [redacted] បូណា ភេទស្រី អាយុ១៤ឆ្នាំ ជាសន្តិសុខរហូតបានសម្រេចនៅចំណុចព្រៃស្វាត់ជិតក្រុមហ៊ុន សន្តិសុខពន្លឺអង្គរស្ថិតនៅ ភូមិល្វប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ខណៈដែលជនរងគ្រោះ ចេញពីធ្វើការ។ ថ្ងៃនោះរ៉ឺម៉ក កង់បីរបស់ក្រុមហ៊ុន មិនបានទៅទទួលជនរងគ្រោះទេ ឆ្លៀតឱកាសពេលនោះជនសង្ស័យឈ្មោះ [redacted] ឡាង ជាមេសន្តិសុខបានសុំឌុប ជនរង

Scanned with CamScanner

គ្រោះទៅផ្ទះ ប៉ុន្តែជននេះមិនឌុបទៅផ្ទះទេ បែរជាឌុបចូលព្រៃស្ងាត់ហើយចាប់រំលោភជនរងគ្រោះតែម្តង។ បន្ទាប់មកជនសង្ស័យ ក៏បានដឹកជនរងគ្រោះមកដាក់មុខក្រុមហ៊ុនវិញរួចក៏ជិះម៉ូតូគេចចេញបាត់តែម្តង បន្ទាប់មកម្តាយជូនគ្រោះក៏បានដាក់ពាក្យបណ្តឹងចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមនីតិវិធីតែម្តង ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៦១៦ អ.យ.ទ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥១២៨ អ.យ.ឆ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦៨៥២ (ឋ) ង.ង ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឡាង អវត្តមាន ដោយគ្មានមូលហេតុ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន អវត្តមាន ដោយគ្មានមូលហេតុ។

-ជនរងគ្រោះឈ្មោះ [redacted] បូណា អវត្តមាន ដោយគ្មានមូលហេតុ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្នើសុំពិនិត្យឯកសារនានាក្នុងសំណុំរឿង ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទពីបទ រំលោភសេពសន្ថវៈ នោះទេ។ ហេតុនេះ តំណាងអយ្យការប្តឹងសុំអោយជនជាប់ចោទរួចផុតពីបទចោទ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ចំពោះអង្គហេតុដែលបានចោទប្រកាន់កូនក្តីខ្លួនថា បានរំលោភសេពសន្ថវៈលើជនរងគ្រោះបានសម្រេចនោះ គឺមិនមានភស្តុតាងគ្រប់គ្រាន់នោះទេ ។ ហេតុនេះ សុំឱ្យតុលាការឱ្យកូនក្តីខ្លួនរួចផុតពីបទចោទផងចុះ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦៨៥២ (ឋ) ង.ង ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនឈ្មោះ [redacted] ឡាង ទៅជំនុំជម្រះពីបទ៖ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចព្រៃស្ងាត់ក្បែរសន្តិសុខក្រុមហ៊ុនពន្លឺអង្គរ ភូមិល្វាប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២-តុលាការបានកោះហៅ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងជនជាប់ចោទ តាមនីតិវិធីរបស់តុលាការ តែដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងជនជាប់ចោទមិនចូលបង្ហាញខ្លួនតាមកាលបរិច្ឆេទកំណត់ទេ ។

៣. តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថា " គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លក់ឪកាស គឺជាបទរំលោភសេពសន្ថវៈ "។ ៗ/

Scanned with CamScanner

-តាមពាក្យបណ្តឹង ក៏ដូចជាការពិនិត្យឯកសារនានាក្នុងសំណុំរឿង ឃើញថា ពុំមានភស្តុតាងដែលអាចបញ្ជាក់ថាជនជាប់ចោទបានធ្វើសកម្មភាពរំលោភលើជនរងគ្រោះ ដូចការចោទប្រកាន់នោះទេ។ ហេតុនេះ គប្បីឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ព្រោះគ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុក ។

៥-ពុំមានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] ឡាង ពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចប្រៃស្ជាត់ក្បែរសន្តិសុខក្រុមហ៊ុនពន្លឺអង្គរ ភូមិល្វប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះសម្រេច**</u>

-ឱ្យឈ្មោះ [redacted] ឡាង ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)រួចផុតពីបទចោទ <u>ពីបទ៖</u> **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចប្រៃស្ជាត់ក្បែរសន្តិសុខក្រុមហ៊ុនពន្លឺអង្គរ ភូមិល្វប្រាំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ប្រកាសជាអសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ និងកំបាំងដើមបណ្តឹងរដ្ឋប្បវេណី ។

រក្សាសិទ្ធិប្តឹងជំទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមក្រុមប្រឹក្សា** | **ចៅក្រមក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខានិងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៦កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]